ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៥៣ សហវ.ប្រក.[illegible]

# ប្រកាស
# ស្តីពី
# ការតែងតាំងសមាសភាពគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នសរ/កម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ | **អូន ព័ន្ធមុនីរ័ត្ន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ជូ វិជិត្ត** | រដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម | **ស៊ាង ផល្លា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម | សមាជិក |
| ៤. ឯកឧត្តម | **ខ៉ាន់ តិរម្យ** | អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិកអចិន្ត្រៃយ៍ |
| ៥. ឯកឧត្តម | **ហ៊ីល បុណ្ណារ័ត្ន** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | សមាជិក |
| ៦. លោកជំទាវ | **ខែត ម៉ូរីឡែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក។ |

**ប្រការ២.-**

គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ធានាឱ្យដំណើរការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មធ្វើឡើងដោយ តម្លាភាព សុចរិតភាព យុត្តិធម៌ អព្យាក្រឹត គ្មានការរើសអើង និងទាន់ពេល
- ពិនិត្យលើបណ្ដឹងតវ៉ា ដែលអ្នកដេញថ្លៃមិនយល់ព្រមតាមការសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- រៀបចំកិច្ចប្រជុំពិនិត្យដោះស្រាយបណ្ដឹងតវ៉ារបស់អ្នកដេញថ្លៃតាមការចាំបាច់
- ស្នើឱ្យអ្នកដេញថ្លៃផ្ដល់ព័ត៌មាន ឬឯកសារភស្ដុតាងបន្ថែម ចំពោះពាក្យប្ដឹងតវ៉ាដែលពុំមានព័ត៌មាន ឬឯកសារភស្ដុតាងគ្រប់គ្រាន់
- អញ្ជើញតំណាងសាមីស្ថាប័នអនុវត្តលទ្ធកម្ម, អ្នកដេញថ្លៃដែលប្ដឹងតវ៉ា, ឬភាគីពាក់ព័ន្ធដទៃទៀត ក្នុងករណីចាំបាច់ ដើម្បីបំភ្លឺ ឬផ្ដល់យោបល់
- ចេញសេចក្ដីសម្រេចស្ដីពីលទ្ធផលនៃការដោះស្រាយបណ្ដឹងតវ៉ាទៅអ្នកដេញថ្លៃដែលប្ដឹងតវ៉ា និងចម្លងជូនស្ថាប័នអនុវត្តលទ្ធកម្ម ព្រមទាំងផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- រក្សាទុកឯកសារពាក់ព័ន្ធនឹងការដោះស្រាយបណ្ដឹងតវ៉ាឱ្យបានត្រឹមត្រូវ។

**ប្រការ៣.-**

- អនុប្រធាននិងសមាជិកនៃគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម ត្រូវអនុវត្តការងារពាក់ព័ន្ធនឹងការដោះស្រាយបណ្ដឹងតវ៉ា និងចូលរួមកិច្ចប្រជុំតាមការណែនាំនិងការអញ្ជើញរបស់ប្រធានគណៈកម្មាធិការនេះ
- ប្រធានគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម មានសិទ្ធិកោះប្រជុំតាមការចាំបាច់ ក្នុងករណីប្រធានគណៈកម្មាធិការអវត្តមានឬមានធុរៈ ប្រធានគណៈកម្មាធិការអាចប្រគល់សិទ្ធិជូនអនុប្រធានគណៈកម្មាធិការ ដឹកនាំកិច្ចប្រជុំជំនួស រួចរាយការណ៍ជូនប្រធានគណៈកម្មាធិការ។

**ប្រការ៤ ._**

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម មាននាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋាននេះមានភារកិច្ចដូចបានកំណត់ក្នុងមាត្រា ២៤ នៃអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹងនិងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម។

**ប្រការ៥ ._**

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ដែលចូលរួមដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីទំនាស់ផលប្រយោជន៍ (ដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ) នៅពេលចូលរួមដោះស្រាយបណ្តឹងតវ៉ានីមួយៗ។

**ប្រការ៦ ._**

ប្រកាសលេខ ៧២១ សហវ.ប្រក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម និងប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុង ប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច

ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីប្រកាសស្តីពីទំនាស់ផលប្រយោជន៍

ខ្ញុំបាទ/នាងខ្ញុំ បានចុះហត្ថលេខាខាងក្រោមនេះ សូមធ្វើការអះអាងថា ខ្ញុំបាទ/នាងខ្ញុំនឹងអនុវត្តឱ្យបានម៉ឺងម៉ាត់ប្រកបដោយតម្លាភាព សុចរិតភាព យុត្តិធម៌ អព្យាក្រឹត គ្មានការរើសអើង និងទាន់ពេល ក្នុងភារកិច្ចពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងតវ៉ា។ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវអំពីទំនាស់ផលប្រយោជន៍ដែលកើតមានលើតថភាពជាក់ស្តែង ឬបច្ច័យដែលនាំឱ្យកើតមានឡើងនូវទំនាស់ផលប្រយោជន៍ ក្នុងអំឡុងអនុវត្តភារកិច្ចរបស់ខ្ញុំបាទ/នាងខ្ញុំពាក់ព័ន្ធនឹងដំណើរការដោះស្រាយបណ្តឹងតវ៉ា។

ខ្ញុំបាទ/នាងខ្ញុំ ជា.........................................សូមធ្វើការអះអាង ដូចខាងក្រោម៖

១. ខ្ញុំបាទ/នាងខ្ញុំ មិនមានពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ខ្លួន, មុខតំណែង, ហិរញ្ញវត្ថុ, ឬផលប្រយោជន៍ដទៃទៀត ដែលនាំឱ្យមានឥទ្ធិពលអវិជ្ជមានទៅលើសមត្ថភាពបំពេញការងាររបស់ខ្ញុំបាទ/នាងខ្ញុំ ក្នុងការពិនិត្យវិនិច្ឆ័យប្រកបដោយយុត្តិធម៌ និងត្រឹមត្រូវលើពាក្យបណ្តឹងដែលបានដាក់ជូនគណៈកម្មាធិការ។

២. ខ្ញុំបាទ/នាងខ្ញុំ យល់ថាទំនាស់ផលប្រយោជន៍អាចកើតមាននៅពេល៖
- ខ្ញុំបាទ/នាងខ្ញុំ មានទំនាក់ទំនងផ្ទាល់ ជាមួយគូភាគីណាមួយដែលពាក់ព័ន្ធក្នុងបណ្តឹងតវ៉ា (ឧ. គ្រួសារ មិត្តជិតស្និទ្ធ ឬភាគីវិវាទ)
- ខ្ញុំបាទ/នាងខ្ញុំ មានទំនាក់ទំនងផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬមុខតំណែង ចំពោះលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា
- ខ្ញុំបាទ/នាងខ្ញុំ ធ្លាប់បានប្រឹក្សាយោបល់ ផ្តល់ជំនួយ ឬតំណាងឱ្យគូភាគីណាមួយដែលពាក់ព័ន្ធក្នុងបណ្តឹងតវ៉ា
- ខ្ញុំបាទ/នាងខ្ញុំ កំពុងកាន់ ឬធ្លាប់បានកាន់មុខតំណែងណាមួយ ដែលនាំឱ្យមានភាពលម្អៀងធ្វើឱ្យប៉ះពាល់ដល់ការវិនិច្ឆ័យរបស់ខ្ញុំបាទ/នាងខ្ញុំ ចំពោះការដោះស្រាយបណ្តឹងតវ៉ា។

៣. ប្រសិនបើនៅពេលណាមួយក្នុងអំឡុងដំណើរការដោះស្រាយបណ្តឹងតវ៉ា ខ្ញុំបាទ/នាងខ្ញុំបានដឹងអំពីទំនាស់ផលប្រយោជន៍ដែលកើតមានលើតថភាពជាក់ស្តែង ឬបច្ច័យដែលនាំឱ្យកើតមានឡើងនូវទំនាស់ផលប្រយោជន៍ ខ្ញុំបាទ/នាងខ្ញុំត្រូវរាយការណ៍ភ្លាមៗជាលាយលក្ខណ៍អក្សរទៅប្រធានគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ហើយដកខ្លួនចេញពីការចូលរួមដោះស្រាយបណ្តឹងតវ៉ានេះ។

ខ្ញុំបាទ/នាងខ្ញុំ បានយល់ដឹងថាការខកខានក្នុងការរាយការណ៍ពីទំនាស់ផលប្រយោជន៍ណាមួយ អាចបណ្តាលឱ្យខ្ញុំបាទ/នាងខ្ញុំ នឹងទទួលរងនូវទណ្ឌកម្ម រួមទាំងការដកចេញពីសមាសភាពគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាផងដែរ។

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥.....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០.....

**ហត្ថលេខានិងឈ្មោះ**